ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



# កម្រងទិន្នន័យបម្រែបម្រួលគម្របព្រៃឈើ
# នៃប្រព័ន្ធតំបន់ការពារធម្មជាតិ
# ឆ្នាំ២០០៦ - ២០១៦

សីហា ២០១៧








# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកធនធានធម្មជាតិជាប្រភពដ៏សំខាន់រួមចំណែកក្នុងការកសាងសេដ្ឋកិច្ច សង្គម កាត់បន្ថយភាពក្រីក្រ ការពារនិងអភិរក្សវប្បធម៌ ជានានិរន្តភាពបរិស្ថាន ជីវៈចម្រុះ និងជួយឱ្យមានលំនឹងអាកាសធាតុ។ ក្រសួងបរិស្ថានសម្រេចបានជោគជ័យលើកំណែទម្រង់វិស័យបរិស្ថាន និងធនធានធម្មជាតិ នាពេលថ្មីៗនេះ ហើយជាលទ្ធផល តំបន់ការពារធម្មជាតិត្រូវបានកើនឡើងដល់៤៥តំបន់ ជាមួយគ្នានេះក៏បានបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ក្នុងគោលបំណងតភ្ជាប់តំបន់ការពារធម្មជាតិទាំងឡាយ ដើម្បីជានាទំនាក់ទំនងចលនាផ្លាស់ទីជីវៈចម្រុះក្នុងព្រះរាជាណាចក្រកម្ពុជា។

កម្រងទិន្នន័យបម្រែបម្រួលគម្របព្រៃឈើនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវបានពិនិត្យរៀបចំឡើង ក្នុងគោលដៅ ធ្វើបច្ចុប្បន្នភាពស្ថិតិទិន្នន័យគម្របព្រៃឈើនៃប្រព័ន្ធតំបន់ការពារធម្មជាតិនៅព្រះរាជាណាចក្រកម្ពុជា ឱ្យមានលក្ខណៈជាប្រព័ន្ធ មានសង្គតិភាពខ្ពស់ ច្បាស់លាស់ និងអាចប្រៀបធៀបបាន និងលើសពីនេះទៅទៀត វាក៏ជួយរំលឹកឡើងវិញអំពីមុខងារ និងតួនាទីនៃប្រភេទតំបន់ការពារធម្មជាតិនីមួយៗ ដល់អ្នកសិក្សាស្រាវជ្រាវផងដែរ។ កម្រងទិន្នន័យបម្រែបម្រួលគម្របព្រៃឈើ គឺជាមូលដ្ឋានព័ត៌មានដ៏រឹងមាំមួយសម្រាប់ប្រើជាជំនួយក្នុងការរៀបចំផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិឆ្នាំ២០១៧-២០៣១ និងផែនការជាតិពាក់ព័ន្ធដទៃទៀត បានប្រកបដោយសង្គតិភាព និងប្រសិទ្ធភាពខ្ពស់ ហើយក៏អាចជាសូចនាករដ៏សំខាន់សម្រាប់ជាមូលដ្ឋានធ្វើការវាស់ស្ទង់នូវកម្រិតលទ្ធផលសម្រេចបានក្នុងវិស័យព្រៃឈើ ទាំងនៅក្នុងក្របខណ្ឌថ្នាក់ជាតិ និងអន្តរជាតិ ជាពិសេសកម្មវិធីរេដបូកកម្ពុជាដែលស្ថិតនៅក្រោមអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

ជារួម កម្រងទិន្នន័យបម្រែបម្រួលគម្របព្រៃឈើ បានបង្ហាញនូវលទ្ធផលជាក់ស្តែងពីការត្រួតពិនិត្យ តាមដាន និងវាយតម្លៃបម្រែប្រមួលគម្របព្រៃឈើ នៃតំបន់ការពារធម្មជាតិ នៅព្រះរាជាណាចក្រកម្ពុជា ក្នុងកំឡុងឆ្នាំ២០០៦ ដល់ ២០១៦ ដោយប្រើប្រាស់បច្ចេកទេសប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (Geographic Imformation Systems) និងរូបភាពផ្កាយរណប (Remote Sensing) ហើយវានឹងត្រូវធ្វើឱ្យមានលក្ខណៈកាន់តែសុក្រឹតខ្ពស់ល្អបន្ថែមទៀតនៅពេលអនាគត។

ក្នុងនាមក្រសួងបរិស្ថាន ខ្ញុំសូមកោតសរសើរចំពោះថ្នាក់ដឹកនាំក្រសួងបរិស្ថាន អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងក្រុមការងារបច្ចេកទេសទាំងអស់ ក្នុងការ

ដឹកនាំ ខិតខំសិក្សាស្រាវជ្រាវ និងរៀបចំឯកសារដ៏មានសារៈសំខាន់នេះរហូតបានសម្រេចជារូបរាងឡើង និងសូមប្រកាសដាក់ឱ្យប្រើប្រាស់ចាប់ពីពេលនេះតទៅ៕

រាជធានីភ្នំពេញ ថ្ងៃទី១១ខែសីហាឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំនៃ ក្រសួងបរិស្ថាន ទាំងមូលដែលបានយកអស់កំលាំងកាយចិត្ត និងប្រាជ្ញាស្មារតី រៀបចំគោលនយោបាយផែនការ យុទ្ធសាស្ត្រគ្រប់គ្រង ការពារ និងអភិរក្សធនធានព្រៃឈើ តំបន់ការពារធម្មជាតិ។ ក្នុងន័យនេះ សៀវភៅ «កម្រងទិន្នន័យបម្រែបម្រួលគម្របព្រៃឈើនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ឆ្នាំ២០០៦-២០១៦» បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ព័ត៌មានទិន្នន័យ សម្រាប់រៀបចំផែនការ គ្រប់គ្រង ការពារ និងអភិរក្សប្រកបដោយនិរន្តភាព។

យើងខ្ញុំជាក្រុមការងារ ក៏សូមអនុញ្ញាតថ្លែងអំណរគុណជាពិសេស ជូនចំពោះអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន និងអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន នៃក្រសួងបរិស្ថាន និងដៃគូអភិវឌ្ឍន៍រួមមាន អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ(FAO) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុនប្រចាំកម្ពុជា(JICA) មូលនិធិភាពជាដៃគូកាបូនព្រៃឈើ(FCPF) អង្គការកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងវិទ្យាស្ថានស្រាវជ្រាវព្រៃឈើ និងផលិតផលព្រៃឈើ(FFPRI) នៃប្រទេសជប៉ុន ដែលបានចូលរួមសហការគាំទ្រក្នុងការរៀបចំបង្កើតសៀវភៅនេះឡើង។

យើងខ្ញុំក៏សង្ឃឹមយ៉ាងមុតមាំថានឹងទទួលបានការគាំទ្រពីសំណាក់ឯកឧត្តម លោកជំទាវ លោក លោកស្រី និងមិត្តភក្តិបរទេសទាំងអស់ ប្រើប្រាស់ជាប្រយោជន៍ដល់ការអនុវត្តការងារប្រចាំថ្ងៃដែលអាចជួបប្រទះដោយហេតុណាមួយ និងអាចទុកជាឯកសារយោង សម្រាប់ប្រើប្រាស់ទៅថ្ងៃមុខ។ តាមរយៈនេះយើងខ្ញុំ សូមសំដែងសេចក្តីរីករាយ និងអំណរគុណទុកជាមុន នូវរាល់ការផ្តល់មតិយោបល់ត្រលប់វិញប្រកបដោយអត្ថន័យកែលម្អស្ថាបនា ដើម្បីក្រុមការងារមានលទ្ធភាពធ្វើការកែតម្រូវភាពខ្វះខាតរបស់ខ្លួន សម្រាប់ការផលិតសៀវភៅលើកក្រោយៗទៀតឱ្យមានភាពកាន់តែល្អប្រសើរជាងនេះ។

ជាចុងបញ្ចប់យើងខ្ញុំសូមគោរពជូនពរ ឯកឧត្តមរដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំទាំងអស់ នៃក្រសួងបរិស្ថាន រួមទាំងមិត្តភក្តិបរទេស ជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

# មាតិកា

**អារម្ភកថា** i
**សេចក្តីថ្លែងអំណរគុណ** iii
១. សេចក្តីផ្តើម ១
២. គោលបំណង ១
៣. តំបន់ការពារធម្មជាតិ ១
៣.១ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ១
៣.២ យុទ្ធសាស្ត្រតំបន់ការពារធម្មជាតិ ១
៣.៣ ប្រព័ន្ធតំបន់ការពារធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ២
៤. ទិន្នន័យគម្របព្រៃឈើ នៃតំបន់ការពារធម្មជាតិ ៤
៤.១ តំបន់ឧទ្យានជាតិ ៤
៤.១.១ ទិន្នន័យគម្របព្រៃឈើនៃតំបន់ឧទ្យានជាតិ ឆ្នាំ២០០៦-២០១៦ ៥
៤.២ តំបន់ដែនជម្រកសត្វព្រៃ ៧
៤.២.១ ទិន្នន័យគម្របព្រៃឈើនៃតំបន់ដែនជម្រកសត្វព្រៃ ឆ្នាំ២០០៦-២០១៦ ៨
៤.៣ តំបន់ការពារទេសភាព ១០
៤.៣.១ ទិន្នន័យគម្របព្រៃឈើនៃតំបន់ការពារទេសភាព ឆ្នាំ២០០៦-២០១៦ ១១
៤.៤ តំបន់ប្រើប្រាស់ច្រើនយ៉ាង ១២
៤.៤.១ ទិន្នន័យគម្របព្រៃឈើនៃតំបន់ប្រើប្រាស់ច្រើនយ៉ាង ឆ្នាំ២០០៦-២០១៦ ១៣
៤.៥ តំបន់រ៉ាមសារ ១៥
៤.៥.១ ស្ថិតិទិន្នន័យធនធានគម្របព្រៃឈើនៃតំបន់រ៉ាមសារ ឆ្នាំ២០០៦-២០១៦ ១៦
៤.៦ តំបន់បេតិកភណ្ឌធម្មជាតិ ១៧
៤.៦.១ ទិន្នន័យគម្របព្រៃឈើនៃតំបន់បេតិកភណ្ឌធម្មជាតិ ឆ្នាំ២០០៦-២០១៦ ១៧
៤.៧ របៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ១៩
៤.៧.១ ទិន្នន័យគម្របព្រៃឈើនៃរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ឆ្នាំ២០០៦-២០១៦ ១៩
៥. បម្រែបម្រួលគម្របព្រៃឈើ នៃតំបន់ការពារធម្មជាតិ ២១
៦. សន្និដ្ឋាន ២៦
**ឯកសារយោង** ២៧

## រូបភាព


រូបភាព១ : ផែនទីប្រព័ន្ធតំបន់ការពារធម្មជាតិ ៣

រូបភាព២ : ផែនទីប្រព័ន្ធតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ៣

រូបភាព៣ : ផែនទីគម្របព្រៃឈើឆ្នាំ២០១៦ នៃតំបន់ឧទ្យានជាតិ ៧

រូបភាព៤ : ផែនទីគម្របព្រៃឈើឆ្នាំ២០១៦ នៃតំបន់ដែនជម្រកសត្វព្រៃ ១០

រូបភាព៥ : ផែនទីគម្របព្រៃឈើឆ្នាំ២០១៦ នៃតំបន់ការពារទេសភាព ១២

រូបភាព៦ : ផែនទីគម្របព្រៃឈើឆ្នាំ២០១៦ នៃតំបន់ប្រើប្រាស់ច្រើនយ៉ាង ១៥

រូបភាព៧ : ផែនទីគម្របព្រៃឈើឆ្នាំ២០១៦ នៃតំបន់រ៉ាមសារ ១៧

រូបភាព៨ : ផែនទីគម្របព្រៃឈើឆ្នាំ២០១៦ នៃតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង ១៨

រូបភាព៩ : ផែនទីគម្របព្រៃឈើឆ្នាំ២០១៦ នៃរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ២១

រូបភាព១០ : ផែនទីបម្រែបម្រួលគម្របព្រៃឈើ នៃតំបន់ឧទ្យានជាតិ ឆ្នាំ២០០៦-២០១៦ ២៣

រូបភាព១១ : ផែនទីបម្រែបម្រួលគម្របព្រៃឈើ នៃតំបន់ដែនជម្រកសត្វព្រៃ ឆ្នាំ២០០៦-២០១៦ ២៣

រូបភាព១២ : ផែនទីបម្រែបម្រួលគម្របព្រៃឈើ នៃតំបន់ការពារទេសភាព ឆ្នាំ២០០៦-២០១៦ ២៤

រូបភាព១៣ : ផែនទីបម្រែបម្រួលគម្របព្រៃឈើ នៃតំបន់ប្រើប្រាស់ច្រើនយ៉ាងឆ្នាំ២០០៦-២០១៦ ២៤

រូបភាព១៤ : ផែនទីបម្រែបម្រួលគម្របព្រៃឈើ នៃតំបន់រ៉ាមសារឆ្នាំ២០០៦-២០១៦ ២៥

រូបភាព១៥ : ផែនទីបម្រែបម្រួលគម្របព្រៃឈើ នៃតំបន់បេតិកភណ្ឌធម្មជាតិឆ្នាំ២០០៦-២០១៦ ២៥

រូបភាព១៦ : ផែនទីបម្រែបម្រួលគម្របព្រៃឈើនៃរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិឆ្នាំ២០០៦-២០១៦ ២៦

## តារាង


តារាង១ : តំបន់ឧទ្យានជាតិ ៥
តារាង២ : ទិន្នន័យគម្របព្រៃឈើនៃតំបន់ឧទ្យានជាតិឆ្នាំ ២០០៦-២០១៦ ៦
តារាង៣ : តំបន់ដែនជម្រកសត្វព្រៃ ៨
តារាង៤ : ទិន្នន័យគម្របព្រៃឈើនៃតំបន់ដែនជម្រកសត្វព្រៃ ឆ្នាំ២០០៦-២០១៦ ៩
តារាង៥ : តំបន់ការពារទេសភាព ១១
តារាង៦ : ទិន្នន័យគម្របព្រៃឈើនៃតំបន់ការពារទេសភាព ឆ្នាំ២០០៦-២០១៦ ១១
តារាង៧ : តំបន់ប្រើប្រាស់ច្រើនយ៉ាង ១៣
តារាង៨ : ទិន្នន័យគម្របព្រៃឈើនៃតំបន់ប្រើប្រាស់ច្រើនយ៉ាង ឆ្នាំ២០០៦-២០១៦ ១៤
តារាង៩ : តំបន់រ៉ាមសារ ១៥
តារាង១០ : ទិន្នន័យគម្របព្រៃឈើនៃតំបន់តំបន់រ៉ាមសារ ឆ្នាំ២០០៦-២០១៦ ១៦
តារាង១១ : ទិន្នន័យគម្របព្រៃឈើនៃតំបន់បេតិកភណ្ឌធម្មជាតិ ឆ្នាំ២០០៦-២០១៦ ១៨
តារាង១២ : របៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ១៩
តារាង១៣ : ទិន្នន័យគម្របព្រៃឈើនៃតំបន់របៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ឆ្នាំ២០០៦-២០១៦ ២០
តារាង១៤ : ស្ថិតិវាយតម្លៃបម្រែបម្រួលគម្របព្រៃឈើ ឆ្នាំ២០០៦-២០១៦ ២២


## ក្រាហ្វិក


ក្រាហ្វិក១ : បម្រែបម្រួលគម្របព្រៃឈើនៃតំបន់ឧទ្យានជាតិ ឆ្នាំ២០០៦-២០១៦ ៦
ក្រាហ្វិក២ : បម្រែបម្រួលគម្របព្រៃឈើនៃតំបន់ដែនជម្រកសត្វព្រៃ ឆ្នាំ២០០៦-២០១៦ ៩
ក្រាហ្វិក៣ : បម្រែបម្រួលធនគម្របព្រៃឈើនៃតំបន់ការពារទេសភាព ឆ្នាំ២០០៦-២០១៦ ១២
ក្រាហ្វិក៤ : បម្រែបម្រួលគម្របព្រៃឈើនៃតំបន់ប្រើប្រាស់ច្រើនយ៉ាង ឆ្នាំ២០០៦-២០១៦ ១៤
ក្រាហ្វិក៥ : បម្រែបម្រួលគម្របព្រៃឈើនៃតំបន់រ៉ាមសារ ឆ្នាំ២០០៦-២០១៦ ១៦
ក្រាហ្វិក៦ : បម្រែបម្រួលគម្របព្រៃឈើនៃតំបន់បេតិកភណ្ឌធម្មជាតិ ឆ្នាំ២០០៦-២០១៦ ១៨
ក្រាហ្វិក៧ : បម្រែបម្រួលគម្របព្រៃឈើនៃរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ឆ្នាំ២០០៦-២០១៦ ២០
ក្រាហ្វិក៨ : បម្រែបម្រួលគម្របព្រៃឈើនៃតំបន់ការពារធម្មជាតិ ឆ្នាំ២០០៦-២០១៦ ២២

## ១.សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា បានកំណត់តំបន់ការពារចំនួន ២៣តំបន់ ក្រោមព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការកំណត់តំបន់ការពារធម្មជាតិ ដែលគ្របដណ្តប់លើផ្ទៃដីសរុបប្រមាណចំនួន ៣,២លានហិកតា ស្មើនឹង១៧ភាគរយ នៃផ្ទៃដីប្រទេស។ តាមរយៈកំណែទម្រង់លើវិស័យគ្រប់គ្រងធនធានធម្មជាតិ ក្នុងអាណត្តិទី៥នៃរាជរដ្ឋាភិបាលកម្ពុជា បច្ចុប្បន្នតំបន់ការពារធម្មជាតិត្រូវបានបង្កើនចំនួនឡើងដល់៤៥តំបន់ និងមានបន្ថែមផ្ទៃដីរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ សរុបមានផ្ទៃដីប្រមាណចំនួន៧,៤លាន ស្មើនឹង៤១ភាគរយ នៃផ្ទៃដីប្រទេស។ តាមរយៈច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៧ បានរៀបចំគ្រប់គ្រងតំបន់ការពារធម្មជាតិ ដោយបែងចែកជាប្រាំបីតំបន់ខុសៗគ្នាក្នុងនោះរួមមានៈ តំបន់ឧទ្យានជាតិ តំបន់ដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង តំបន់រ៉ាមសារ តំបន់បេតិកភណ្ឌធម្មជាតិ តំបន់ស្នូលនៃឋបនីយជីវមណ្ឌល និងតំបន់ឧទ្យានជាតិសមុទ្រ។

## ២. គោលបំណង

ធ្វើបច្ចុប្បន្នភាពទិន្នន័យធនធានគម្របព្រៃឈើនៅក្នុងតំបន់ការពារធម្មជាតិទាំង៤៥តំបន់ និង របៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ សម្រាប់ជាមូលដ្ឋានគ្រឹះក្នុងការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនានារបស់ក្រសួងបរិស្ថាន។

## ៣. តំបន់ការពារធម្មជាតិ

### ៣.១ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

ច្បាប់ស្តីពីតំបន់ការពារធម្មជាតិដែលរដ្ឋសភាជាតិបានអនុម័តកាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ មានវិសាលភាពអនុវត្តនៅតំបន់ការពារធម្មជាតិដែលកំណត់ដោយបទបញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស.រកម ១២៩៦-៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦។ គោលបំណងនៃច្បាប់នេះ គឺធានានូវការគ្រប់គ្រង ការអភិរក្សជីវៈចម្រុះ និងការធានាប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ការពារប្រកបដោយនិរន្តភាព។

### ៣.២ យុទ្ធសាស្ត្រតំបន់ការពារធម្មជាតិ

ក្រសួងបរិស្ថាន ត្រូវធ្វើផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ។ ផែនការយុទ្ធសាស្ត្រនេះ មានលក្ខណៈស្របគ្នាជាមួយផែនការនានារបស់ជាតិ ដូចជា ផែនការបរិស្ថានជាតិ ផែនការយុទ្ធសាស្ត្រជាតិ និងសកម្មភាពជាតិស្តីពីជីវៈចម្រុះ និងផែនការតំបន់ដីសើម។ យោងតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ជំពូកទី៥ មាត្រា១៥ ផែនការយុទ្ធសាស្ត្រ

ជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ត្រូវសម្រេចដោយរាជរដ្ឋាភិបាលតាមការស្នើសុំរបស់ក្រសួងបរិស្ថាន។

ផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ត្រូវមានចែងអំពី ៖

- គោលបំណងនៃការអភិរក្ស ការស្តារ ការទប់ស្កាត់ បង្ក្រាបបទល្មើស និងការប្រើប្រាស់ដោយនិរន្តភាពនូវធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ីរបស់តំបន់ការពារធម្មជាតិនីមួយៗ
- ស្ថានភាពបច្ចុប្បន្ននៃធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ីរបស់តំបន់នីមួយៗ រួមទាំងប្រភេទសត្វ រុក្ខជាតិ សេនេទិច សេដ្ឋកិច្ចសង្គម និងវប្បធម៌
- សក្តានុពលនៃតំបន់ការពារធម្មជាតិនីមួយៗ ដើម្បីសម្រេចឱ្យបាននូវគោលបំណងនៃកិច្ចការពារ អភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិ
- អនុសាសន៍ អំពីវិធានការធ្វើឱ្យសម្រេចនូវគោលបំណងនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ។

### ៣.៣ ប្រព័ន្ធតំបន់ការពារធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា

បច្ចុប្បន្នកម្ពុជាបានបង្កើនតំបន់ការពារធម្មជាតិចំនួនដល់៤៥តំបន់ និងបង្កើតរបៀងអភិរក្សជីវៈចម្រុះសម្រាប់តភ្ជាប់ប្រព័ន្ធតំបន់ការពារធម្មជាតិ គ្របដណ្តប់លើផ្ទៃដីសរុបប្រមាណ ៧,៤លានហិកតា (រូបភាព១ និងរូបភាព២)។ ដោយឡែកតំបន់ការពារធម្មជាតិ ចែកចេញជា ៨ ប្រភេទ មានដូចខាងក្រោម៖

| | |
|---|---|
| ១.តំបន់ឧទ្យានជាតិ | ២.តំបន់ដែនជម្រកសត្វព្រៃ |
| ៣.តំបន់ការពារទេសភាព | ៤.តំបន់ប្រើប្រាស់ច្រើនយ៉ាង |
| ៥.តំបន់រ៉ាមសារ | ៦.តំបន់ស្នូលនៃបម្រុងជីវមណ្ឌល |
| ៧.តំបន់បេតិកភណ្ឌធម្មជាតិ | ៨.តំបន់ឧទ្យានជាតិសមុទ្រ |




**រូបភាព១**: ផែនទីប្រព័ន្ធតំបន់ការពារធម្មជាតិ




**រូបភាព២**: ផែនទីប្រព័ន្ធតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ

## ៤. ទិន្នន័យគម្របព្រៃឈើនៃតំបន់ការពារធម្មជាតិ

### ៤.១ តំបន់ឧទ្យានជាតិ

តំបន់ឧទ្យានជាតិ សំដៅដល់តំបន់ធម្មជាតិក្នុងដែនដីគោក និង/ឬ ដែនទឹកដែលត្រូវបានកំណត់ ដើម្បី៖

ក. ការពារតួនាទីខាងផ្នែកប្រព័ន្ធអេកូឡូស៊ីមួយ ឬ ច្រើន របស់តំបន់ដែលបានកំណត់សម្រាប់ជាប្រយោជន៍ដល់មនុស្សគ្រប់ជំនាន់

ខ. កំរិតដល់ការប្រើប្រាស់ ដែលអាចធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញដល់ធនធានជីវៈចម្រុះ ធនធានធម្មជាតិ ធនធានវប្បធម៌ និងមុខងារតួនាទីរបស់តំបន់នោះជាមួយនឹងគោលបំណងនៃការកំណត់តំបន់

គ. ផ្តល់ជាមូលដ្ឋានសម្រាប់ការកំសាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងជំនឿដែលគ្រប់សកម្មភាពទាំងនេះ ពុំបង្កការគម្រាមកំហែងដល់បរិស្ថានធម្មជាតិ និងវប្បធម៌នៅក្នុងមូលដ្ឋាន។

ឧទ្យានជាតិចំនួន៧តំបន់ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ និងមានទីតាំងចំនួន៥តំបន់ ទៀតត្រូវបានបង្កើតឡើងដោយអនុក្រឹត្យក្នុងឆ្នាំ២០១៦។ ឧទ្យានជាតិទាំង១២តំបន់នេះ គ្របដណ្តប់លើផ្ទៃដីសរុប១.៧២០.២៦៩,៣៥ហិកតា ដែលស្មើនឹង៩,៥ភាគរយ នៃផ្ទៃដីប្រទេស ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ កោះកុង កំពត ពោធិ៍សាត់ សៀមរាប រតនគិរី ព្រះសីហនុ និងខេត្តស្ទឹងត្រែង (តារាង១ តំបន់ឧទ្យានជាតិ)។

**តារាង១:** តំបន់ឧទ្យានជាតិ

| ល.រ | តំបន់ឧទ្យានជាតិ | ទីតាំងភូមិសាស្ត្រ (ខេត្ត) | ផ្ទៃក្រឡា (ហ.ត) | ព្រះរាជក្រឹត្យ/អនុក្រឹត្យ | |
|---|---|---|---|---|---|
| | | | | លេខ | ថ្ងៃ ខែ ឆ្នាំ |
| ១ | ព្រះសុរាម្រិត-កុសមៈ (គិរីរម្យ) | កំពង់ស្ពឺ កំពត និង ព្រះសីហនុ | ៣៥.២៣២ | ១៧១ អនក្រ.បក | ២៨ ធ្នូ ២០១០ |
| ២ | ព្រះមុនីវង្ស (បូកគោ) | កំពត និងព្រះសីហនុ | ១៥៤.៤៥៨ | ១៧១ អនក្រ.បក | ២៨ ធ្នូ ២០១០ |
| ៣ | កែប | កែប | ១.១៥២ | ១៣៨ អនក្រ.បក | ២៥ តុលា ២០០៣ |
| ៤ | ព្រះសីហនុ (រាម) | ព្រះសីហនុ | ១៥.០០០ | នស/រកត/០៧ | ០១ វិច្ឆិកា ១៩៩៣ |
| ៥ | បុទុមសាគរ | កោះកុង | ១៧១.២៥០ | នស/រកត/០៧ | ០១ វិច្ឆិកា ១៩៩៣ |
| ៦ | ព្រះជ័យវរ្ម័ន-នរោត្តម (ភ្នំគូលែន) | សៀមរាប | ៣៧.៥០០ | នស/រកត/០៧ | ០១ វិច្ឆិកា ១៩៩៣ |
| ៧ | វីរៈជ័យ | រតនៈគិរី និងស្ទឹងត្រែង | ៣៣២.៥០០ | នស/រកត/០៧ | ០១ វិច្ឆិកា ១៩៩៣ |
| ៨ | វីនសៃ-សៀមប៉ាង | ស្ទឹងត្រែង និងរតនៈគិរី | ៥៧.៤៦៩ | ៧៧ អនក្រ.បក | ០៩ ឧសភា ២០១៦ |
| ៩ | ជួរភ្នំក្រវាញកណ្ដាល | កោះកុង ពោធិ៍សាត់ និង កំពង់ស្ពឺ | ៤០១.៣១៣ | ៨១ អនក្រ.បក | ០៩ ឧសភា ២០១៦ |
| ១០ | អូរយ៉ាដាវ | រតនៈគិរី | ១០១.៣៤៨ | ៨២ អនក្រ.បក | ០៩ ឧសភា ២០១៦ |
| ១១ | ជួរភ្នំក្រវាញខាងត្បូង | កោះកុង ពោធិ៍សាត់ កំពង់ស្ពឺ និងព្រះសីហនុ | ៤១០.៣៩២ | ៨៩ អនក្រ.បក | ០៩ ឧសភា ២០១៦ |
| ១២ | កោះរុង | ព្រះសីហនុ | ២.៦៥៥,៣៥ | ១៨៨ អនក្រ.បក | ១៣ កញ្ញា ២០១៦ |
| | **ផ្ទៃដីសរុប** | | **១.៧២០.២៦៩,៣៥** | | |

### ៤.១.១ ទិន្នន័យគម្របព្រៃឈើនៃតំបន់ឧទ្យានជាតិ ឆ្នាំ២០០៦-២០១៦

តាមរយៈការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០០៦កន្លងមក បានបង្ហាញថា ឧទ្យានជាតិទាំង១២តំបន់ គ្របដណ្តប់លើផ្ទៃដីព្រៃឈើសរុបចំនួន ១.៥៩២.៩៨៦ហិកតា ស្មើនឹង ៩៣,៧ភាគរយ ធៀបនឹងផ្ទៃដីតំបន់សរុប។ ដោយឡែក លទ្ធផលនៃការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០១៦ បង្ហាញថាមានផ្ទៃដីគម្របព្រៃឈើនៅសល់ចំនួន ១.៥៦១.៩៤៤ហិកតា ស្មើនឹង ៩១,៩ភាគរយ ធៀបនឹងផ្ទៃដីតំបន់សរុប។ លទ្ធផលទិន្នន័យវាយតម្លៃគម្របព្រៃឈើ នៃតំបន់ឧទ្យានជាតិ មានបង្ហាញក្នុងតារាងខាងក្រោម៖

**តារាង២: ទិន្នន័យគម្របព្រៃឈើ នៃតំបន់ឧទ្យានជាតិ ឆ្នាំ២០០៦-២០១៦**

| លរ | តំបន់ឧទ្យានជាតិ | ផ្ទៃដីគម្របព្រៃឈើ | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០០៦ | | ២០១០ | | ២០១៤ | | ២០១៦ | |
| | | ហិកតា | % | ហិកតា | % | ហិកតា | % | ហិកតា | % |
| ១ | ព្រះសុរាម្រិត-កុសមៈ (គិរីរម្យ) | ៣៤.៤៣៣ | ៩៧,៨ | ៣៤.៤៧២ | ៩៧,៨ | ៣៤.១៨១ | ៩៧,០ | ៣៣.៩០២ | ៩៦,២ |
| ២ | ព្រះមុនីវង្ស (បូកគោ) | ១៤៧.៣១៣ | ៩៥,៤ | ១៤៧.១៨៦ | ៩៥,៣ | ១៣៨.៨២៣ | ៨៩,៩ | ១៣៦.៦១០ | ៨៨,៤ |
| ៣ | កែប | ១.០០០ | ៨៦.៧ | ១.០០០ | ៨៦,៧ | ៩៥៥ | ៨២,៨ | ៩២៣ | ៨០,១ |
| ៤ | ព្រះសីហនុ (រាម) | ១៣.១៩៥ | ៧១,៤ | ១៣.០៧៤ | ៧០,៨ | ១១.៨២៦ | ៦៤,០ | ១១.៣២៨ | ៦១,៣ |
| ៥ | បុទុមសាគរ | ១១៧.១៣៦ | ៧៩.៩ | ១១៧.៤២១ | ៨០,០ | ១០៩.៧២៥ | ៧៤,៨ | ១០៨.៨៨៥ | ៧៤,១ |
| ៦ | ព្រះជ័យវរ្ម័ន-នរោត្តម(ភ្នំគូលែន) | ៣២.៤៦៣ | ៨៦,៩ | ៣២.៧២៥ | ៨៧,៦ | ២៨.៩៣០ | ៧៧,៤ | ២០.៧៤៧ | ៥៥,៥ |
| ៧ | វិរៈជ័យ | ៣៣០.៣៧៣ | ៩៨,៩ | ៣៣០.៩៣៩ | ៩៩,០ | ៣៣០.១៧៧ | ៩៨,៨ | ៣២៩.៥២៤ | ៩៨,៦ |
| ៨ | វ៉ុនសៃ-សៀមប៉ាង | ៥៥.៦១០ | ៩៦,៨ | ៥៦.១៩២ | ៩៧,៨ | ៥៥.៨៤៤ | ៩៧,២ | ៥៥.៦៧៨ | ៩៦,៩ |
| ៩ | ជួរភ្នំក្រវាញកណ្តាល | ៣៧៣.៨៤១ | ៩៣,២ | ៣៧៧.៩០០ | ៩៤,២ | ៣៧៥.៤២២ | ៩៣,៦ | ៣៨៣.៤៩៣ | ៩៥,៦ |
| ១០ | អូរយ៉ាដាវ | ៩៥.៩២១ | ៩៥,៨ | ៩៥.២៨០ | ៩៤,១ | ៩៥.១៤១ | ៩៤,០ | ៩២.៨១៨ | ៩១,៧ |
| ១១ | ជួរភ្នំក្រវាញខាងត្បូង | ៣៨៩.២៦៧ | ៩៤,៩ | ៣៩១.៤៩៧ | ៩៥,៤ | ៣៨១.៨៤៨ | ៩៣,០ | ៣៨៥.៨៥៩ | ៩៤,០ |
| ១២ | កោះរុង | ២.៤១៤ | ៩៥,៩ | ២.៤១៤ | ៩៥,៩ | ២.១៧៧ | ៨៦,៥ | ២.១៧៧ | ៨៦,៥ |
| | **ផ្ទៃដីសរុប** | **១.៥៩២.៩៨៦** | **៩៣,៧** | **១.៦០០.១០០** | **៩៤,១** | **១.៥៦៥.០៤៩** | **៩២,០** | **១.៥៦១.៩៤៤** | **៩១,៩** |

បញ្ជាក់៖ ទិន្នន័យផ្ទៃដីតារាងខាងលើ ជាការគណនាតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS)




**ក្រាហ្វិក១: បម្រែបម្រួលគម្របព្រៃឈើនៃតំបន់ឧទ្យានជាតិ ឆ្នាំ២០០៦-២០១៦**




**រូបភាព៣**: ផែនទីគម្របព្រៃឈើឆ្នាំ២០១៦ នៃតំបន់ឧទ្យានជាតិ

### ៤.២ តំបន់ដែនជម្រកសត្វព្រៃ

តំបន់ដែនជម្រកសត្វព្រៃសំដៅដល់តំបន់ក្នុងដែនដីគោក ឬដែនទឹក ដែលតម្រូវឱ្យមានការធ្វើអន្តរាគមន៍យ៉ាងសកម្ម សម្រាប់បំពេញគោលបំណងគ្រប់គ្រង ដើម្បីធានាឱ្យមានការថែទាំទីជម្រកនិង/ឬដើម្បីបំពេញលក្ខខណ្ឌចាំបាច់សម្រាប់ប្រភេទណាមួយនៃសត្វឬរុក្ខជាតិ។

ដែនជម្រកសត្វព្រៃចំនួន១០តំបន់ ត្រូវបានបង្កើតឡើងដោយ ព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ និងមានទីតាំងចំនួន៨តំបន់ទៀត ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យក្នុងឆ្នាំ២០១៦។ ដែនជម្រកសត្វព្រៃទាំង១៨តំបន់នេះ គ្របដណ្តប់នៅលើផ្ទៃដីសរុបចំនួន៣.៦៨៤.៣២៨ហិកតា ដែលស្មើ២០,៣ភាគរយ នៃផ្ទៃដីប្រទេស ស្ថិតក្នុងខេត្តសៀមរាប ព្រះវិហារ កោះកុង ពោធិ៍សាត់ កំពង់ឆ្នាំង បាត់ដំបង កំពង់ធំ រតនគិរី និងខេត្តមណ្ឌលគិរី ( តារាង៣ តំបន់ដែនជម្រកសត្វព្រៃ )។

**តារាង៣:** តំបន់ដែនជម្រកសត្វព្រៃ

| ល.រ | តំបន់ដែនជម្រកសត្វព្រៃ | ទីតាំងភូមិសាស្ត្រ (ខេត្ត) | ផ្ទៃក្រឡា (ហ.ត) | ព្រះរាជក្រឹត្យ/អនុក្រឹត្យ | |
|---|---|---|---|---|---|
| | | | | លេខ | ថ្ងៃ ខែ ឆ្នាំ |
| ១ | ភ្នំឱរ៉ាល់ | កំពង់ស្ពឺ ពោធិ៍សាត់ កំពង់ឆ្នាំង | ២៥៣.៧៥០ | នស/រកត/០៧ | ០១ វិច្ឆិកា ១៩៩៣ |
| ២ | ពាមក្រសោប | កោះកុង | ២៣.៧៥០ | នស/រកត/០៧ | ០១ វិច្ឆិកា ១៩៩៣ |
| ៣ | ភ្នំសំកុស | ពោធិ៍សាត់ បាត់ដំបង និង កោះកុង | ៣៣៣.៧៥០ | នស/រកត/០៧ | ០១ វិច្ឆិកា ១៩៩៣ |
| ៤ | រនាមដូនសំ | បាត់ដំបង | ១៧៨.៧៥០ | នស/រកត/០៧ | ០១ វិច្ឆិកា ១៩៩៣ |
| ៥ | គូលែន-ព្រហ្មទេព | សៀមរាប ព្រះវិហារ និង កំពង់ធំ | ៤០២.៥០០ | នស/រកត/០៧ | ០១ វិច្ឆិកា ១៩៩៣ |
| ៦ | បឹងពែរ | សៀមរាប ព្រះវិហារ និង កំពង់ធំ | ២៤២.៥០០ | នស/រកត/០៧ | ០១ វិច្ឆិកា ១៩៩៣ |
| ៧ | លំផាត់ | រតនៈគិរី និងមណ្ឌលគិរី | ២៥០.០០០ | ០៤ អនក្រ.បក | ០៥ មករា ២០១៧ |
| ៨ | ភ្នំព្រេច | មណ្ឌលគិរី | ២២២.៥០០ | ០៥ អនក្រ.បក | ០៥ មករា ២០១៧ |
| ៩ | ភ្នំណាមលៀរ | មណ្ឌលគិរី | ៤៧.៥០០ | នស/រកត/០៧ | ០១ វិច្ឆិកា ១៩៩៣ |
| ១០ | ស្នួល | ក្រចេះ | ៧៥.០០០ | នស/រកត/០៧ | ០១ វិច្ឆិកា ១៩៩៣ |
| ១១ | ព្រៃឡង់ | ស្ទឹងត្រែង កំពង់ធំ ក្រចេះ និង ព្រះវិហារ | ៤៣១.៦៨៣ | ៧៤ អនក្រ.បក | ០៩ ឧសភា ២០១៦ |
| ១២ | ព្រះរការ | ព្រះវិហារ | ៩០.៣៦១ | ៧៥ អនក្រ.បក | ០៩ ឧសភា ២០១៦ |
| ១៣ | សៀមប៉ាងខាងលិច | ស្ទឹងត្រែង | ៦៥.៣៨៩ | ៧៦ អនក្រ.បក | ០៩ ឧសភា ២០១៦ |
| ១៤ | ឆែប | ព្រះវិហារ និងស្ទឹងត្រែង | ១៩០.០២៧ | ៧៩ អនក្រ.បក | ០៩ ឧសភា ២០១៦ |
| ១៥ | តាតៃ | កោះកុង | ១៤៤.២៧៥ | ៨០ អនក្រ.បក | ០៩ ឧសភា ២០១៦ |
| ១៦ | កែវសីមា | មណ្ឌលគិរី និងក្រចេះ | ២៩២.៦៩០ | ៨៣ អនក្រ.បក | ០៩ ឧសភា ២០១៦ |
| ១៧ | ស្រែពក | មណ្ឌលគិរី | ៣៧២.៩៧១ | ៨៥ អនក្រ.បក | ០៩ ឧសភា ២០១៦ |
| ១៨ | សៀមប៉ាង | ស្ទឹងត្រែង | ៦៦.៩៣២ | ៨៦ អនក្រ.បក | ០៩ ឧសភា ២០១៦ |
| | **ផ្ទៃដីសរុប** | | ៣.៦៨៤.៣២៨ | | |

## ៤.២.១ ទិន្នន័យគម្របព្រៃឈើនៃតំបន់ដែនជម្រកសត្វព្រៃ ឆ្នាំ២០០៦-២០១៦

តាមរយៈការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០០៦កន្លងមក បានបង្ហាញថាដែនជម្រកសត្វព្រៃទាំង១៨តំបន់ គ្របដណ្តប់លើផ្ទៃដីព្រៃឈើសរុបចំនួន ៣.៣០២.៩០៨ហិកតា ស្មើនឹង ៩២,៩ភាគរយ ធៀបនឹងផ្ទៃដីតំបន់សរុប។ ដោយឡែក លទ្ធផលនៃការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០១៦ បានបង្ហាញថាមានផ្ទៃដីព្រៃឈើនៅសល់ចំនួន ២.៨៣៦.៧៦៥ហិកតា ស្មើនឹង ៧៩,៨ភាគរយ ធៀបនឹងផ្ទៃដីតំបន់សរុប ។ លទ្ធផលទិន្នន័យវាយតម្លៃគម្របព្រៃឈើ នៃតំបន់ដែនជម្រកសត្វព្រៃ មានបង្ហាញក្នុងតារាងខាងក្រោម៖

## តារាង៤: ទិន្នន័យគម្របព្រៃឈើ នៃតំបន់ដែនជម្រកសត្វព្រៃ ឆ្នាំ២០០៦-២០១៦

| លរ | តំបន់ដែនជម្រកសត្វព្រៃ | ផ្ទៃដីគម្របព្រៃឈើ ២០០៦ | | ២០១០ | | ២០១៤ | | ២០១៦ | |
|---|---|---|---|---|---|---|---|---|---|
| | | ហិកតា | % | ហិកតា | % | ហិកតា | % | ហិកតា | % |
| ១ | ភ្នំឱរ៉ាល់ | ២៤៦.៩៨៩ | ៩៧,២ | ២៤៦.៧៨៨ | ៩៧,១ | ១៩៩.៧៩៨ | ៧៧,០ | ១៩១.២៣០ | ៧៥,២ |
| ២ | ពាមក្រសោប | ១៦.៩៩២ | ៦៨,៧ | ១៧.៤២៩ | ៧០,៤ | ១៥.៨៤៥ | ៦៤,០ | ១៥.៧៨៥ | ៦០,៩ |
| ៣ | ភ្នំសំកុស | ៣១៧.៥៨៥ | ៩៦,៣ | ៣១៥.៨១៦ | ៩៥,៨ | ២៧៤.២៥៩ | ៨៣,២ | ២៦៩.៩៧៧ | ៨១,៩ |
| ៤ | រនាមដូនសំ | ១៤.៣០១ | ៣៥,៧ | ៩.៩៨០ | ២៤,៩ | ៣.៥៧៨ | ៨,៩ | ២.៤៩៩ | ៦,២ |
| ៥ | គូលែន-ព្រហ្មទេព | ៣៧៨.៩០៤ | ៩២,៥ | ៣៦៧.០៨០ | ៨៩,៦ | ២៦៥.៨៥៩ | ៦៤,៩ | ២៥៣.៩៤៦ | ៦២,០ |
| ៦ | បឹងពែរ | ២២១.៩៧៤ | ៨៨,៩ | ២១៩.២៧០ | ៨៧,៨ | ១៥២.៤៨៣ | ៦១,១ | ១៣៦.៩២៨ | ៥៤,៨ |
| ៧ | លំផាត់ | ២២៨.០៩០ | ៩០,៣ | ២២៨.១៨១ | ៩០,៤ | ២១៩.៦០៥ | ៨៧,០ | ២០៥.៤៣០ | ៨១,៤ |
| ៨ | ភ្នំព្រេច | ២១១.៦៨២ | ៩៦,៦ | ២១២.០១៣ | ៩៦,៨ | ២១១.៨០២ | ៩៦,៧ | ២០៩.៩០៧ | ៩៥,៨ |
| ៩ | ភ្នំណាមលៀរ | ៤២.៥២៥ | ៩២,៩ | ៤២.០៩៣ | ៩១,៩ | ៣៧.៧៤៩ | ៨២,៥ | ៣៦.៩០១ | ៨០,៦ |
| ១០ | ស្នួល | ៦២.៦៤៣ | ៨៣,៤ | ៦១.១៩៩ | ៨០,១ | ១៩.៩៧៩ | ២៦,៦ | ១៣.៧៦៨ | ១៨,៣ |
| ១១ | ព្រៃឡង់ | ៤២៣.៤៩៦ | ៩៨,១ | ៤២៣.១១៩ | ៩៨,០ | ៤១៩.០០៩ | ៩៧,១ | ៤១៣.៣៨០ | ៩៥,៨ |
| ១២ | ព្រះរការ | ៩០.០៧២ | ៩៩,៧ | ៩០.០៣៧ | ៩៩,៦ | ៨៩.៣១៣ | ៩៨,៨ | ៨៩.១៧០ | ៩៨,៧ |
| ១៣ | សៀមប៉ាងខាងលិច | ៦២.៣៩៣ | ៩៣,៥ | ៦២.៦១៩ | ៩៣,៨ | ៦០.៨៦៥ | ៩១,២ | ៦០.៧៤៣ | ៩១,០ |
| ១៤ | ឆែប | ១៨៣.២៨៤ | ៩៦,៥ | ១៨២.៩៧៤ | ៩៦,៣ | ១៧៣.៤១២ | ៩១,៣ | ១៧១.៧៦០ | ៩០,៤ |
| ១៥ | តាតៃ | ១២៧.០៥៧ | ៨៨,១ | ១២៩.២៦៥ | ៨៩,៦ | ១២៧.២៧៣ | ៨៨,២ | ១២៧.៤៦៣ | ៨៨,៣ |
| ១៦ | កែវសីមា | ២៦៧.៧០៧ | ៩១,៥ | ២៦៨.៣២៨ | ៩១,៧ | ២៤៨.២៧៩ | ៨៤,៨ | ២៣១.៤៨៦ | ៧៩,១ |
| ១៧ | ស្រែពក | ៣៤៥.០៩៣ | ៩២,៩ | ៣៤៥.៤៤២ | ៩២,៩ | ៣៤៤.៤០៥ | ៩២,៧ | ៣៤៣.៣២០ | ៩២,៤ |
| ១៨ | សៀមប៉ាង | ៦២.១២១ | ៩២,៨ | ៦២.៧៧២ | ៩៣,៨ | ៦២.៨៣៥ | ៩៣,៩ | ៦៣.០៧២ | ៩៤,២ |
| | **ផ្ទៃដីសរុប** | **៣.៣០២.៩០៨** | **៩២,៩** | **៣.២៨៣.៤០៥** | **៩២,៤** | **២.៩២២.៣៤៨** | **៨២,២** | **២.៨៣៦.៧៦៥** | **៧៩,៨** |

បញ្ជាក់៖ ទិន្នន័យផ្ទៃដីតារាងខាងលើ ជាការគណនាតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS)




**ក្រាហ្វិក២:** បម្រែបម្រួលគម្របព្រៃឈើនៃតំបន់ដែនជម្រកសត្វព្រៃ ឆ្នាំ២០០៦-២០១៦



**រូបភាព៤**: ផែនទីគម្របព្រៃឈើឆ្នាំ២០១៦ នៃតំបន់ដែនជម្រកសត្វព្រៃ

## ៤.៣ តំបន់ការពារទេសភាព

តំបន់ការពារទេសភាព សំដៅដល់តំបន់នៃដែនដីគោក និង/ឬ ដែនទឹក ដែលតំបន់នោះទទួលរងអន្តរអំពើរបស់មនុស្ស ទៅលើធម្មជាតិ ដោយបង្កើតបានជាតំបន់ដែលមានលក្ខណៈប្លែកខាងផ្នែកសោភ័ណ្ឌភាពធម្មជាតិ ឬកេរ្តិ៍ អេកូឡូស៊ី ឬវប្បធម៌ និងជាទូទៅសម្បូណ៌ដោយជីវៈចម្រុះ។

តំបន់ការពារទេសភាពចំនួន៣តំបន់ ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ និងមានទីតាំងចំនួន៥តំបន់ទៀត ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យក្នុងឆ្នាំ២០១៦។ បច្ចុប្បន្ន តំបន់ការពារទេសភាពទាំង៨តំបន់ គ្របដណ្តប់នៅលើផ្ទៃដីចំនួនប្រមាណ១៤៩.៣៤៧,៣០ហិកតា ដែលស្មើនឹង ០,៨ភាគរយ នៃផ្ទៃដីប្រទេស ស្ថិតនៅក្នុងខេត្តសៀមរាប បន្ទាយមានជ័យ ព្រះវិហារ កំពត កំពង់ធំ តាកែវ និងខេត្តព្រះសីហនុ (តារាង៥ តំបន់ការពារទេសភាព)។

**តារាង៥:** តំបន់ការពារទេសភាព

| ល.រ | តំបន់ការពារទេសភាព | ទីតាំងភូមិសាស្ត្រ (ខេត្ត) | ផ្ទៃក្រឡា (ហ.ត) | ព្រះរាជក្រឹត្យ/អនុក្រឹត្យ | |
|---|---|---|---|---|---|
| | | | | លេខ | ថ្ងៃ ខែ ឆ្នាំ |
| ១ | អង្គរ | សៀមរាប | ១០.៨០០ | នស/រកត/០៧ | ០១ វិច្ឆិកា ១៩៩៣ |
| ២ | បន្ទាយឆ្មារ | បន្ទាយមានជ័យ និងឧត្តរមានជ័យ | ៨១.២០០ | នស/រកត/០៧ | ០១ វិច្ឆិកា ១៩៩៣ |
| ៣ | ព្រះវិហារ | ព្រះវិហារ | ៥.០០០ | នស/រកត/០៧ | ០១ វិច្ឆិកា ១៩៩៣ |
| ៤ | អន្លង់ព្រីង | កំពត | ២១៧ | ០៤ អនក្រ.បក | ០៦ មករា ២០១១ |
| ៥ | ទំនាបខាងជើងទន្លេសាប | កំពង់ធំ សៀមរាប | ៣១.១៥៩ | ៨៨ អនក្រ.បក | ០៩ ឧសភា ២០១៦ |
| ៦ | បឹងព្រែកល្ពៅ | តាកែវ | ៨.៣០៥ | ១៤៩ អនក្រ.បក | ១៥ តុលា ២០០៧ |
| ៧ | អាងត្រពាំងថ្ម | បន្ទាយមានជ័យ | ១២.៦៥០ | ជស/រកត/០២០០/១១០ | ២២ កុម្ភៈ ២០០០ |
| ៨ | បឹងព្រែកទប់ | ព្រះសីហនុ | ១៦,៣០ | ១៨៧ អនក្រ.បក | ១៣ កញ្ញា ២០១៦ |
| | **សរុបផ្ទៃដី** | | **១៤៩.៣៤៧,៣០** | | |

## ៤.៣.១ ទិន្នន័យគម្របព្រៃឈើនៃតំបន់ការពារទេសភាព ឆ្នាំ២០០៦-២០១៦

តាមរយៈការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០០៦កន្លងមក បានបង្ហាញថាតំបន់ការពារទេសភាពទាំង៨តំបន់ គ្របដណ្តប់លើផ្ទៃដីព្រៃឈើសរុបចំនួន ៥៤.៦៣៣ហិកតា ស្មើនឹង ៣៥,៥ភាគរយ ធៀបនឹងផ្ទៃដីតំបន់សរុប។ ដោយឡែក លទ្ធផលនៃការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០១៦ បង្ហាញថាមានផ្ទៃដីព្រៃឈើនៅសល់ចំនួន ២៦.០២៥ហិកតា ស្មើនឹង១៦,៩ភាគរយធៀបនឹងផ្ទៃដីតំបន់សរុប។ លទ្ធផលទិន្នន័យវាយតម្លៃគម្របព្រៃឈើ នៃតំបន់ការពារទេសភាព មានបង្ហាញក្នុងតារាងខាងក្រោម៖

**តារាង៦:** ទិន្នន័យគម្របព្រៃឈើនៃតំបន់ការពារទេសភាព ឆ្នាំ២០០៦-២០១៦

| ល.រ | តំបន់ការពារទេសភាព | ផ្ទៃដីគម្របព្រៃឈើ | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០០៦ | | ២០១០ | | ២០១៤ | | ២០១៦ | |
| | | ហិកតា | % | ហិកតា | % | ហិកតា | % | ហិកតា | % |
| ១ | អង្គរ | ៣.១៣៤ | ២២,៨ | ៣.៤០៦ | ២៤,៨ | ៤.២០៨ | ៣០,៦ | ៤.០៥០ | ២៩,៥ |
| ២ | បន្ទាយឆ្មារ | ៣៥.៧១៨ | ៤២,១ | ៣១.៩១៦ | ៣៧,៦ | ១០.៦៣៨ | ១២,៥ | ៨.០១០ | ៩,៤ |
| ៣ | ព្រះវិហារ | ៣.១៨៥ | ៩៩,១ | ៣.១៧៦ | ៩៨,៨ | ២.៨៥៣ | ៨៨,៨ | ២.៨៥២ | ៨៨,៨ |
| ៤ | អន្លង់ព្រីង | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ៥ | ទំនាបខាងជើងទន្លេសាប | ១១.៥៨១ | ៣៧,២ | ១២.០៤៩ | ៣៨,៧ | ១១.០៦៣ | ៣៥,៥ | ១១.០១០ | ៣៥,៣ |
| ៦ | បឹងព្រែកល្ពៅ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ៧ | អាងត្រពាំងថ្ម | ១.០១៥ | ៨,០ | ៩១១ | ៣,៥ | ២៦៩ | ២,១ | ១០៣ | ០,៨ |
| ៨ | បឹងព្រែកទប់ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| | **សរុបផ្ទៃដី** | **៥៤.៦៣៣** | **៣៥,៥** | **៥១.៤៥៨** | **៣៣,៤** | **២៩.០៣១** | **១៨,៨** | **២៦.០២៥** | **១៦,៩** |

បញ្ជាក់៖ ទិន្នន័យផ្ទៃដីតារាងខាងលើជាការគណនាតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS)




**ក្រាហ្វិក៣:** បម្រែបម្រួលគម្របព្រៃឈើនៃតំបន់ការពារទេសភាព ឆ្នាំ២០០៦-២០១៦



**រូបភាព៩:** ផែនទីគម្របព្រៃឈើឆ្នាំ២០១៦ នៃតំបន់ការពារទេសភាព

### ៤.៤.តំបន់ប្រើប្រាស់ច្រើនយ៉ាង

តំបន់ប្រើប្រាស់ច្រើនយ៉ាង សំដៅដល់តំបន់ក្នុងដែនដីគោក និង/ឬដែនទឹក ដែលក្នុងនោះមានសម្បូណ៌ដោយប្រព័ន្ធធម្មជាតិ ដែលពុំទាន់រងការបំផ្លិចបំផ្លាញ និងតម្រូវឱ្យមានសកម្មភាពគ្រប់គ្រង ដើម្បីធានាការការពារ ការថែទាំធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី សម្រាប់ពេល

យូរអង្វែង។ ទន្ទឹមនឹងនោះដែរ អាចផ្តល់ផលិតផល និងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់តាមតម្រូវការរបស់សហគមន៍។

តំបន់ប្រើប្រាស់ច្រើនយ៉ាងចំនួន៣តំបន់ ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ និងទីតាំងចំនួន២តំបន់ទៀត ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យក្នុងឆ្នាំ២០១៦។ តំបន់ប្រើប្រាស់ច្រើនយ៉ាងទាំង៥តំបន់ គ្របដណ្តប់នៅលើផ្ទៃដីសរុបចំនួន ៤០៩.៦៦៩ហិកតា ដែលស្មើនឹង២,៣ភាគរយ នៃផ្ទៃដីប្រទេស ស្ថិតនៅក្នុងខេត្តសៀមរាប កោះកុង បាត់ដំបង កំពង់ធំ កំពង់ឆ្នាំង ប៉ៃលិន ពោធិ៍សាត់ ត្បូងឃ្មុំ និងខេត្តព្រះសីហនុ (តារាង៧ តំបន់ប្រើប្រាស់ច្រើនយ៉ាង)។

តារាង៧: តំបន់ប្រើប្រាស់ច្រើនយ៉ាង

| ល.រ | តំបន់ប្រើប្រាស់ច្រើនយ៉ាង | ទីតាំងភូមិសាស្ត្រ (ខេត្ត) | ផ្ទៃក្រឡា (ហ.ត) | ព្រះរាជក្រឹត្យ/អនុក្រឹត្យ | |
|---|---|---|---|---|---|
| | | | | លេខ | ថ្ងៃ ខែ ឆ្នាំ |
| ១ | ដងពែង | កោះកុង | ២៧.៧០០ | នស/រកត/០៧ | ០១ វិច្ឆិកា ១៩៩៣ |
| ២ | សំឡូត | ប៉ៃលិន និងបាត់ដំបង | ៦០.០០០ | នស/រកត/០៧ | ០១ វិច្ឆិកា ១៩៩៣ |
| ៣ | ទន្លេសាប | កំពង់ធំ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង និងសៀមរាប | ៣១៦.២៥០ | នស/រកត/០៧ | ០១ វិច្ឆិកា ១៩៩៣ |
| ៤ | ពញាក្រែក | ត្បូងឃ្មុំ | ១៩៩ | ៨៧ អនក្រ.បក | ០៩ ឧសភា ២០១៦ |
| ៥ | ព្រែកទឹកសាបក្បាលឆាយ | ព្រះសីហនុ | ៥.៥២០ | ១១៦ អនក្រ.បក | ០៥ មិថុនា ២០១៦ |
| | **សរុបផ្ទៃដី** | | ៤០៩.៦៦៩ | | |

### ៤.៤.១ ទិន្នន័យគម្របព្រៃឈើនៃតំបន់ប្រើប្រាស់ច្រើនយ៉ាង ឆ្នាំ២០០៦-២០១៦

តាមរយៈការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០០៦កន្លងមក បានបង្ហាញថា តំបន់ប្រើប្រាស់ច្រើនយ៉ាងទាំង៥តំបន់ គ្របដណ្តប់លើផ្ទៃដីព្រៃឈើសរុបចំនួន ២៨៩.៥៤០ហិកតា ស្មើនឹង ៦៧,៩ភាគរយ ធៀបនឹងផ្ទៃដីតំបន់សរុប។ ដោយឡែក លទ្ធផលនៃការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០១៦ បង្ហាញថាមានផ្ទៃដីព្រៃឈើនៅសល់ប្រមាណ២៨៤.៥៩៦ហិកតា ស្មើនឹង៦៦,៧ភាគរយ ធៀបនឹងផ្ទៃដីតំបន់សរុប។ លទ្ធផលទិន្នន័យវាយតម្លៃគម្របព្រៃឈើនៃតំបន់ប្រើប្រាស់ច្រើនយ៉ាង មានបង្ហាញក្នុងតារាងខាងក្រោម៖

**តារាង៨: ទិន្នន័យគម្របព្រៃឈើ នៃតំបន់ប្រើប្រាស់ច្រើនយ៉ាង ឆ្នាំ២០០៦-២០១៦**

| ល.រ | តំបន់ប្រើប្រាស់ច្រើនយ៉ាង | ផ្ទៃដីគម្របព្រៃឈើ | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០០៦ | | ២០១០ | | ២០១៤ | | ២០១៦ | |
| | | ហិកតា | % | ហិកតា | % | ហិកតា | % | ហិកតា | % |
| ១ | ដងពែង | ១៣.០២០ | ៤៦,១ | ១៣.៥៥៩ | ៤៨,០ | ១២.៥៧០ | ៤៤,០ | ១២.៤៨០ | ៤៤,២ |
| ២ | សំឡូត | ៥១.៤០០ | ៨៤,៣ | ៤៩.១២៩ | ៨០,៥ | ៤៧.២៥៩ | ៧៧,៥ | ៤៦.៦១៩ | ៧៦,៤ |
| ៣ | ទន្លេសាប | ២២១.៣១១ | ៦៦,៨ | ២៣៨.៨២២ | ៧២,១ | ២១៧.៤៨៣ | ៦៥,៦ | ២២០.៨៥៩ | ៦៦,៦ |
| ៤ | ពញាក្រែក | ០ | ០ | ០ | ០ | ១៦៣ | ៩១,៥ | ១៦១ | ៩១,៥ |
| ៥ | ព្រែកទឹកសាបក្បាលឆាយ | ៣.៨០៩ | ៦៩,០ | ៤.៤៤២ | ៨០,៥ | ៤.៥៣៩ | ៨២,២ | ៤.៣៧៧ | ៧៩,៣ |
| | **សរុបផ្ទៃដី** | **២៨៩.៥៤០** | **៦៧,៩** | **៣០៥.៩៥២** | **៧១,៨** | **២៨២.០១២** | **៦៦,១** | **២៨៤.៤៩៦** | **៦៦,៧** |

បញ្ជាក់៖ទិន្នន័យផ្ទៃដីតារាងខាងលើជាការគណនាតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS)




**ក្រាហ្វិក៤:** បម្រែបម្រួលគម្របព្រៃឈើនៃតំបន់ប្រើប្រាស់ច្រើនយ៉ាង ឆ្នាំ២០០៦-២០១៦




**រូបភាព៦**: ផែនទីគម្របព្រៃឈើឆ្នាំ២០១៦ នៃតំបន់ប្រើប្រាស់ច្រើនយ៉ាង

## ៤.៥.តំបន់រ៉ាមសារ

តំបន់រ៉ាមសារ សំដៅដល់តំបន់ដីសើម ដែលគេចាត់ទុកថាជាតំបន់មានសារៈសំខាន់ផ្នែកអេកូឡូស៊ី ឬជីវៈចម្រុះជាលក្ខណៈអន្តរជាតិ។

តំបន់រ៉ាមសារចំនួន៣តំបន់ ត្រូវបានបង្កើតឡើងដោយព្រះរាជក្រម ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និងមានទីតាំងចំនួន១តំបន់ ទៀតត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៥។ តំបន់រ៉ាមសារទាំង៤ តំបន់ គ្របដណ្តប់នៅលើផ្ទៃដីសរុបចំនួន៥១.៧០២ ហិកតា ដែលស្មើនឹង០,៣ភាគរយ នៃផ្ទៃដីប្រទេស ស្ថិតនៅក្នុងខេត្តស្ទឹងត្រែង កោះកុង បាត់ដំបង និងខេត្តកំពង់ធំ(តារាង៩ តំបន់រ៉ាមសារ)។

**តារាង៩**: តំបន់រ៉ាមសារ

| ល.រ | តំបន់រ៉ាមសារ | ទីតាំងភូមិសាស្ត្រ (ខេត្ត) | ផ្ទៃក្រឡា(ហ.ត) | ព្រះរាជក្រឹត្យ/អនុក្រឹត្យ | |
|---|---|---|---|---|---|
| | | | | លេខ | ថ្ងៃ ខែ ឆ្នាំ |
| ១ | ស្ទឹងត្រែង | ស្ទឹងត្រែង | ១៤.៦០០ | នស.រកម.១២៩៦.៣៤ | ២៤ ធ្នូ ១៩៩៦ |
| ២ | កោះកាពិ | កោះកុង | ១.២០០ | នស.រកម.១២៩៦.៣៤ | ២៤ ធ្នូ ១៩៩៦ |
| ៣ | បឹងទន្លេឆ្មារ | កំពង់ធំ | ១៤.៥៦០ | នស.រកម.១២៩៦.៣៤ | ២៤ ធ្នូ ១៩៩៦ |
| ៤ | ស្នួលព្រែកទាល់ | បាត់ដំបង | ២១.៣៤២ | ១៣៩ អនក្រ.បក | ០២ តុលា ២០១៥ |
| | **ផ្ទៃដីសរុប** | | **៥១.៧០២** | | |

### ៤.៥.១ ទិន្នន័យគម្របព្រៃឈើនៃតំបន់រ៉ាមសារ ឆ្នាំ២០០៦-២០១៦

តាមរយៈការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០០៦កន្លងមក បានបង្ហាញថាក្នុងតំបន់រ៉ាមសារទាំង៤តំបន់ គ្របដណ្តប់លើផ្ទៃដីព្រៃឈើសរុបចំនួន ៣៨.៩៩៣ហិកតា ស្មើនឹង៦២,៧ភាគរយធៀបនឹងផ្ទៃដីតំបន់សរុប។ ដោយឡែក លទ្ធផលនៃការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០១៦ បង្ហាញថាមានផ្ទៃដីព្រៃឈើសរុបចំនួន ៣៩.៧០៣ហិកតា ស្មើនឹង៦៣,៨ភាគរយធៀបនឹងផ្ទៃដីតំបន់សរុប។ លទ្ធផលទិន្នន័យវាយតម្លៃគម្របព្រៃឈើ នៃតំបន់តំបន់រ៉ាមសារ មានបង្ហាញក្នុងតារាងខាងក្រោម៖

**តារាង១០:** ទិន្នន័យគម្របព្រៃឈើ នៃតំបន់រ៉ាមសារ ឆ្នាំ២០០៦-២០១៦

| ល.រ | តំបន់រ៉ាមសារ | ផ្ទៃដីគម្របព្រៃឈើ | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០០៦ | | ២០១០ | | ២០១៤ | | ២០១៦ | |
| | | ហិកតា | % | ហិកតា | % | ហិកតា | % | ហិកតា | % |
| ១ | ស្ទឹងត្រែង | ៣.៩៨២ | ២៦,៨ | ៤.០៨៦ | ២៧,៥ | ៤.៥៥៥ | ៣០,៦ | ៤.៥៤៤ | ៣០,៥ |
| ២ | កោះកាពិ | ៧.៩៥៤ | ៦៩,៥ | ៨.២៥៦ | ៧២,១ | ៧.៥៣២ | ៦៥,៨ | ៧.៥២១ | ៥៥,៨ |
| ៣ | បឹងទន្លេឆ្មារ | ៦.៣៤៤ | ៤៣,៦ | ៦.៦៩៣ | ៤៦,០ | ៧.១២១ | ៤៨,៩ | ៧.១០៥ | ៤៨,៨ |
| ៤ | ស្ទួលព្រែកទាល់ | ២០.៧១៣ | ៩៧,០ | ២០.៨៥៥ | ៩៧,៧ | ២០.៤៧៨ | ៩៥,៩ | ២០.៥៣៣ | ៩៦,២ |
| | **ផ្ទៃដីសរុប** | **៣៨.៩៩៣** | **៦២,៧** | **៣៩.៨៩០** | **៦៤,១** | **៣៩.៦៨៦** | **៦៣,៨** | **៣៩.៧០៣** | **៦៣,៨** |

បញ្ជាក់៖ ទិន្នន័យផ្ទៃដីតារាងខាងលើ ជាការគណនាតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS)




**ក្រាហ្វិក៥:** បម្រែបម្រួលគម្របព្រៃឈើនៃតំបន់រ៉ាមសារ ឆ្នាំ២០០៦-២០១៦




**រូបភាព៧**: ផែនទីគម្របព្រៃឈើឆ្នាំ២០១៦ នៃតំបន់រ៉ាមសារ

### ៤.៦.តំបន់បេតិកភណ្ឌធម្មជាតិ

តំបន់បេតិកភណ្ឌធម្មជាតិសំដៅដល់តំបន់ក្នុងដែនដីគោក និង/ឬ ដែនទឹក ដែលតំបន់នោះមានលក្ខណៈពិសេសពីធម្មជាតិឬពាក់កណ្ដាលកែច្នៃធម្មជាតិ និងមានតម្លៃលេចធ្លោ ឬប្លែកពីគេ ដោយសារតំបន់នោះមានដោយកម្រ មានគុណភាពជាតំណាងឱ្យប្រព័ន្ធធម្មជាតិនានា ឬមានគុណភាពខាងផ្នែកសោភ័ណ្ឌភាព ឬសារៈសំខាន់ខាងផ្នែកវប្បធម៌។

តំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ គ្របដណ្ដប់លើផ្ទៃដីសរុបចំនួន ២៤.៦៥៤ហិកតា ស្ថិតក្នុងខេត្តព្រះវិហារ។

### ៤.៦.១ ទិន្នន័យគម្របព្រៃឈើ នៃតំបន់បេតិកភណ្ឌធម្មជាតិ ឆ្នាំ២០០៦-២០១៦

តាមរយៈការវាយតម្លៃធនធានគម្របព្រៃឈើឆ្នាំ២០១៦ បានបង្ហាញថា តំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង គ្របដណ្ដប់លើផ្ទៃដីព្រៃឈើសរុបចំនួន ២៣.០៦៨ហិកតា ដែលស្មើនឹង៩៣,៦ ភាគរយ នៃផ្ទៃដីតំបន់សរុប ។

**តារាង១១:** ទិន្នន័យវាយតម្លៃគម្របព្រៃឈើ នៃតំបន់បេតិកភណ្ឌធម្មជាតិ ឆ្នាំ២០០៦-២០១៦

| ល.រ | តំបន់បេតិកភណ្ឌធម្មជាតិ | ផ្ទៃដីគម្របព្រៃឈើ | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០០៦ | | ២០១០ | | ២០១៤ | | ២០១៦ | |
| | | ហិកតា | % | ហិកតា | % | ហិកតា | % | ហិកតា | % |
| ១ | ភ្នំត្បែង | ២២.៩៣០ | ៩៣,០ | ២៣.០១១ | ៩៣,៣ | ២៣.២៨០ | ៩៤,៤ | ២៣.០៦៨ | ៩៣,៦ |

បញ្ជាក់៖ ទិន្នន័យផ្ទៃដីតារាងខាងលើ ជាការគណនាតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS)




**ក្រាហ្វិក៦:** បម្រែបម្រួលគម្របព្រៃឈើនៃតំបន់បេតិកភណ្ឌធម្មជាតិឆ្នាំ២០០៦-២០១៦




**រូបភាព២៨:** ផែនទីគម្របព្រៃឈើឆ្នាំ២០១៦ នៃតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង

### ៤.៧.របៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ

របៀងអភិរក្សជីវៈចម្រុះដែលត្រូវបានបង្កើតសម្រាប់តភ្ជាប់តំបន់ការពារធម្មជាតិ ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានជាអាទិ៍ តំបន់ឧទ្យានជាតិ តំបន់ដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង តំបន់រ៉ាមសារ តំបន់បេតិកភណ្ឌធម្មជាតិ តំបន់ស្នូលនៃឋបនីយជីវមណ្ឌល និងតំបន់ឧទ្យានជាតិសមុទ្រ និងសម្រាប់ទ្រទ្រង់សារព័នមជ្ឈដ្ឋានធម្មជាតិនៃតំបន់ប្រព័ន្ធអេកូឡូស៊ី។

របៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវបានបែងចែកជាបីរួមមានៈ របៀងអភិរក្សជីវៈចម្រុះឦសាន របៀងអភិរក្សជីវៈចម្រុះឧត្តរ និងរបៀងអភិរក្សជីវៈចម្រុះជួរភ្នំក្រវាញ ដោយអនុក្រឹត្យ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ គ្របដណ្តប់លើផ្ទៃដីសរុបចំនួន ១.៤២៧.៩៤០ហិកតា ស្មើនឹង៧,៩ភាគរយ នៃផ្ទៃដីប្រទេស (តារាង១២ របៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ) ។

**តារាង១២:** របៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ

| ល.រ | របៀងអភិរក្សជីវៈចម្រុះ | ផ្ទៃក្រឡា(ហ.ត) | ព្រះរាជក្រឹត្យ/អនុក្រឹត្យ | |
|---|---|---|---|---|
| | | | លេខ | ថ្ងៃ ខែ ឆ្នាំ |
| ១.១ | របៀងអភិរក្សជីវៈចម្រុះឦសាន | ៧៥៧.៦៦១ | ០៧ អនក្រ.បក | ២៦ មករា ២០១៧ |
| ១.២ | របៀងអភិរក្សជីវៈចម្រុះឧត្តរ | ៥០០.៨១០ | ០៧ អនក្រ.បក | ២៦ មករា ២០១៧ |
| ១.៣ | របៀងអភិរក្សជីវៈចម្រុះជួរភ្នំក្រវាញ | ១៦៩.៤៦៩ | ០៧ អនក្រ.បក | ២៦ មករា ២០១៧ |
| | **ផ្ទៃដីសរុប** | **១.៤២៧.៩៤០** | | |

#### ៤.៧.១ ទិន្នន័យគម្របព្រៃឈើ នៃរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ឆ្នាំ២០០៦-២០១៦

តាមរយៈការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០០៦កន្លងមក បានបង្ហាញថា របៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ គ្របដណ្តប់លើផ្ទៃដីព្រៃឈើសរុបចំនួន១.៣៤៣.៧៣០ហិកតា ស្មើនឹង៩៤,១ភាគរយ ធៀបនឹងផ្ទៃដីតំបន់សរុប។ ដោយឡែក លទ្ធផលការវាយតម្លៃធនធានគម្របព្រៃឈើឆ្នាំ២០១៦ បង្ហាញថាផ្ទៃដីព្រៃឈើនៅសល់ចំនួន ១.៣១៦.២៨៨ហិកតា ស្មើនឹង៩២,២ភាគរយ ធៀបនឹងផ្ទៃដីតំបន់សរុប។ ទិន្នន័យវាយតម្លៃគម្របព្រៃឈើ នៃរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ មានបង្ហាញក្នុងតារាងខាងក្រោមៈ

**តារាង១៣:** ទិន្នន័យគម្របព្រៃឈើនៃរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ឆ្នាំ២០០៦-២០១៦

| ល.រ | របៀងអភិរក្សជីវៈចម្រុះ | ផ្ទៃដីគម្របព្រៃឈើ | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០០៦ | | ២០១០ | | ២០១៤ | | ២០១៦ | |
| | | ហិកតា | % | ហិកតា | % | ហិកតា | % | ហិកតា | % |
| ១ | របៀងអភិរក្សជីវៈចម្រុះ ព្លសាន | ៤៨៥.៩០២ | ៩៧,០ | ៤៨៥.០២៧ | ៩៦,៩ | ៤៧០.៨១៤ | ៩៤,០ | ៤៥៩.០៩១ | ៩១,៧ |
| ២ | របៀងអភិរក្សជីវៈចម្រុះឧត្តរ | ៦៩៦.៩២៧ | ៩២,០ | ៦៩៩.៧៧៣ | ៩២,៤ | ៦៩៦.០៥៦ | ៩១,៩ | ៦៩៨.១១៦ | ៩២,១ |
| ៣ | របៀងអភិរក្សជីវៈចម្រុះជួរភ្នំក្រវាញ | ១៦០.៩០១ | ៩៤,៩ | ១៦២.៧០២ | ៩៦,០ | ១៦០.០៧៣ | ៩៤,៥ | ១៥៩.០៨១ | ៩៣,៩ |
| | **ផ្ទៃដីសរុប** | **១.៣៤៣.៧៣០** | **៩៤,១** | **១.៣៤៧.៥០២** | **៩៤,៤** | **១.៣២៦.៩៤៣** | **៩២,៩** | **១.៣១៦.២៨៨** | **៩២,២** |

បញ្ជាក់៖ ទិន្នន័យផ្ទៃដីតារាងខាងលើ ជាការគណនាតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS)




ក្រាហ្វិក៧: បម្រែបម្រួលគម្របព្រៃឈើនៃរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ឆ្នាំ២០០៦-២០១៦



**រូបភាព៩**: ផែនទីធនធានគម្របព្រៃឈើឆ្នាំ២០១៦ នៃរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ

## ៥.បម្រែបម្រួលគម្របព្រៃឈើ នៃតំបន់ការពារធម្មជាតិ

តាមរយៈការវាយតម្លៃបម្រែបម្រួលគម្របព្រៃឈើក្នុងតំបន់ការពារធម្មជាតិក្នុងអំឡុងឆ្នាំ២០០៦រហូតដល់ឆ្នាំ២០១៦ បានបង្ហាញថាអត្រាគម្របព្រៃឈើមានការថយចុះ៣,១ភាគរយនៃផ្ទៃដីសរុបទូទាំងប្រទេសក្នុងរយៈពេល១០ឆ្នាំនេះ។ ទន្ទឹមនឹងនេះតាមរយៈការវាយតម្លៃទិន្នន័យគម្របព្រៃឈើនៅក្នុងតំបន់ការពារធម្មជាតិនីមួយៗ ឃើញថាការបាត់បង់គម្របព្រៃឈើក្នុងតំបន់ដែនជម្រកសត្វព្រៃមានអាត្រាខ្ពស់ជាងគេ ដោយក្នុងអំឡុងឆ្នាំ២០០៦-២០១០ មានអត្រាថយចុះ០,១ភាគរយ នឹងអំឡុងឆ្នាំ២០១០-២០១៤ មានអត្រាថយចុះ២ភាគរយដោយឡែកក្នុងរយៈពេលពីរឆ្នាំចុងក្រោយមានការថយចុះតែ០,៥ភាគរយ នៃផ្ទៃដីប្រទេស (តារាង១៤ ស្ថិតិវាយតម្លៃបម្រែបម្រួលគម្របព្រៃឈើ ឆ្នាំ២០០៦-២០១៦)។

**តារាង១៤:** ស្ថិតិវាយតម្លៃបម្រែបម្រួលគម្របព្រៃឈើ ឆ្នាំ២០០៦-២០១៦

| ល.រ | តំបន់ការពារធម្មជាតិ | បម្រែបម្រួលគម្របព្រៃឈើ | | | | | |
|---|---|---|---|---|---|---|---|
| | | ២០០៦-២០១០ | | ២០១០-២០១៤ | | ២០១៤-២០១៦ | |
| | | ហ.ត | % | ហ.ត | % | ហ.ត | % |
| ១ | តំបន់ឧទ្យានជាតិ | ៧.១១៤ | 0,0 | -៣៥.០៥១ | -0,២ | -៣.១០៥ | -0,0 |
| ២ | តំបន់ដែនជម្រកសត្វព្រៃ | -១៩.៥០៣ | -0,១ | -៣៦១.០៥៧ | -២,0 | -៨៥.៥៨៣ | -0,៥ |
| ៣ | តំបន់ការពារទេសភាព | -៣.១៧៥ | 0,0 | -២២.៤២៧ | -0,១ | -៣.០០៦ | -0,0 |
| ៤ | តំបន់ប្រើប្រាស់ច្រើនយ៉ាង | ១៦.៤១២ | 0,១ | -២៣.៩៤០ | -0,១ | ២.៤៨៤ | 0,0 |
| ៥ | តំបន់រ៉ាមសារ | ៨៩៧ | 0,0 | -២០៤ | 0,0 | ១៧ | 0,0 |
| ៦ | តំបន់បេតិកភណ្ឌធម្មជាតិ | ៨១ | 0,0 | ២៧០ | 0,0 | -២១៣ | 0,0 |
| ៧ | របៀងអភិរក្សជីវៈចម្រុះ | ៣.៧៧២ | 0,0 | -២០.៥៥៩ | -0,១ | -១០.៦៥៥ | -0,១ |
| | **ផ្ទៃដីសរុប** | **៥.៥៩៨** | **0.0** | **-៤៦២.៩៦៨** | **-២.៥** | **-២៣៣.៦៤៩** | **-0.៦** |




**ក្រាហ្វិក៨:** បម្រែបម្រួលគម្របព្រៃឈើនៃតំបន់ការពារធម្មជាតិ ឆ្នាំ២០០៦-២០១៦

យោងតាមក្រាហ្វិកខាងលើបញ្ជាក់ថា ស្ថានភាពកម្រិតយោងព្រៃឈើជាពិសេសក្នុងអំឡុងឆ្នាំ២០១០-២០១៤ នៅក្នុងតំបន់ការពារធម្មជាតិដោយគិតជាមធ្យមប្រចាំឆ្នាំបានថយចុះប្រមាណ0,៦២ភាគរយ នៃផ្ទៃដីប្រទេស ដោយគិតជាមធ្យមប្រចាំឆ្នាំមានអត្រាថយចុះគួរឱ្យកត់សម្គាល់ បើប្រៀបធៀបនឹងរយៈពេល២ឆ្នាំចុងក្រោយនេះ ដោយមានជាមធ្យមប្រចាំឆ្នាំថយចុះប្រមាណតែ0,៣ភាគរយ ប៉ុណ្ណោះ។ លទ្ធផលនេះ បង្ហាញឱ្យឃើញថាអត្រាបាត់បង់ធនធានគម្របព្រៃឈើក្នុងតំបន់ការពារធម្មជាតិមានការធ្លាក់ចុះជាមធ្យមប្រចាំឆ្នាំប្រមាណ0,៣២ភាគរយ ទាបជាងអំឡុងពេលពីឆ្នាំ២០១០-២០១៤ កន្លងមក។

តាមការព្យាករណ៍ទុក នៅរយៈពេល២ឆ្នាំខាងមុខទៀតអត្រានៃការបាត់បង់ធនធានព្រៃឈើនេះនឹងបន្តការធ្លាក់ចុះជាបន្តទៀត មូលហេតុនេះដោយសារប្រសិទ្ធភាពនៃការអនុវត្តកំណែទម្រង់លើការគ្រប់គ្រង និងអភិរក្សតំបន់ការពារធម្មជាតិរបស់រាជរដ្ឋាភិបាលក៏ដូចជាការ

ចូលរួមពីសហគមន៍មូលដ្ឋានពីកំលាំងប្រដាប់អាវុធ និងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ក្នុងការទប់ស្កាត់បទល្មើសព្រៃឈើ។




**រូបភាព១០**: ផែនទីបម្រែបម្រួលគម្របព្រៃឈើនៃតំបន់ឧទ្យានជាតិ ឆ្នាំ២០០៦-២០១៦




**រូបភាព១១**: ផែនទីបម្រែបម្រួលគម្របព្រៃឈើនៃតំបន់ដែនជម្រកសត្វព្រៃឆ្នាំ២០០៦-២០១៦




**រូបភាព១២**: ផែនទីបម្រែបម្រួលគម្របព្រៃឈើនៃតំបន់ការពារទេសភាព ឆ្នាំ២០០៦-២០១៦




**រូបភាព១៣**: ផែនទីបម្រែបម្រួលគម្របព្រៃឈើនៃតំបន់ប្រើប្រាស់ច្រើនយ៉ាងឆ្នាំ២០០៦-២០១៦



**រូបភាព១៤**: ផែនទីបម្រែបម្រួលគម្របព្រៃឈើនៃតំបន់រ៉ាមសារ ឆ្នាំ២០០៦-២០១៦



**រូបភាព១៥**: ផែនទីបម្រែបម្រួលគម្របព្រៃឈើនៃតំបន់បេតិកភណ្ឌធម្មជាតិឆ្នាំ២០០៦-២០១៦



**រូបភាព១៦**: ផែនទីបម្រែបម្រួលគម្របព្រៃឈើ នៃរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិឆ្នាំ២០០៦-២០១៦

## ៦. សន្និដ្ឋាន

ការសិក្សាអំពីបច្ចុប្បន្នភាពធនធានគម្របព្រៃឈើ នៃតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ គឺពិតជាព័ត៌មានទិន្នន័យមួយដ៏សំខាន់ ក្នុងការតាមដាននូវបម្រែបម្រួលធនធានធម្មជាតិ គម្របព្រៃឈើនៃតំបន់ការពារធម្មជាតិ។ លទ្ធផលនៃការវាយតម្លៃធនធានគម្របព្រៃឈើក្នុងរយៈពេល១០ឆ្នាំ នៃតំបន់ការពារធម្មជាតិទាំង៤៥ តំបន់ រួមទាំងរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិដោយគិតពីឆ្នាំ២០០៦ដល់ឆ្នាំ ២០១៦ បានបង្ហាញថាការប្រែប្រួលជាមធ្យមប្រចាំឆ្នាំមានចំនួន០,៣ភាគរយ ស្មើនឹងអត្រាថយចុះធនធានគម្របព្រៃឈើចំនួន៥៥.៧៤៣ហិកតា។

តាមរយៈសៀវភៅកម្រងទិន្នន័យបម្រែបម្រួលគម្របព្រៃឈើនៃប្រព័ន្ធតំបន់ការពារធម្មជាតិនេះ គឺជាមូលដ្ឋានព័ត៌មានដ៏រឹងមាំមួយសម្រាប់ប្រើជាជំនួយ ដើម្បីរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ សម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិប្រកបដោយសង្គតិភាព និងប្រសិទ្ធភាពខ្ពស់ ហើយក៏ជាសូចនាករដ៏សំខាន់មួយសម្រាប់ធ្វើការវាស់ស្ទង់នូវកម្រិតលទ្ធផលសម្រេចបានក្នុងការគ្រប់គ្រងវិស័យព្រៃឈើនៅកម្ពុជា៕

## ឯកសារយោង

ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ,ក្រសួងបរិស្ថាន១៥/០២/២០០៨
សៀវភៅធនធានគម្របព្រៃឈើ ឆ្នាំ២០១៤
សៀវភៅធនធានគម្របព្រៃឈើ ឆ្នាំ២០១០
សៀវភៅបម្រែបម្រួលធនធានគម្របព្រៃឈើ ឆ្នាំ២០០២-២០០៦

**ក្រសួងបរិស្ថាន**

**អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ**

អគារមរតកតេជោ ដីឡូលេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន ភ្នំពេញ

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង:

Tel: ០១២ ៤៨៨ ៣៣៩, Email: sophyra.sar@gmail.com

Tel: ០១៧ ៩៥៥ ៨១១, Email: netnorint@gmail.com

ផលិតដោយៈ ក្រុមការងារបច្ចេកទេសប្រព័ន្ធព័ត៌មាន (REDD+) នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ